# សេចក្តីថ្លែងការណ៍របស់ចៅក្រមអន្តរជាតិ

ចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានសេចក្តីសោមនស្សរីករាយ ដែលបានទទួលដំណឹងអំពីការសម្រេចថ្មីៗរបស់ក្រុមប្រឹក្សានៃគណៈមេធាវីកម្ពុជា ដែលបង្កើតថ្លៃសារុបតែមួយគឺស្មើនឹង៥០០ដុល្លារសម្រាប់ការចុះឈ្មោះមេធាវីអន្តរជាតិទាំងអស់ដែលការពារក្តីនៅចំពោះមុខតុលាការ។

ចៅក្រមអន្តរជាតិមានទំនុកចិត្តថាតម្លៃនេះនឹងមិនរារាំងមេធាវីអន្តរជាតិ ជាពិសេស មេធាវីទាំងឡាយដែលការពារក្តីដោយមិនយកកម្រៃ ពីការចុះឈ្មោះនៅគណៈមេធាវីកម្ពុជា និងពីការចូលរួមក្នុងការងារជាប្រវត្តិសាស្ត្រនៃអង្គជំនុំជម្រះវិសាមញ្ញនេះ។

ជាមួយនឹងសេចក្តីសម្រេចនេះ ចៅក្រមអន្តរជាតិជឿថា កិច្ចប្រជុំពេញអង្គនឹងចាប់ផ្តើមឡើង ដើម្បីអនុម័តវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញប្រកបដោយជោគជ័យ ។ មានការរង់ចាំដោយសង្ឃឹម ថាកិច្ចប្រជុំពេញអង្គនេះនឹងត្រូវធ្វើឡើងនៅសប្តាហ៍ចុងក្រោយនៃខែឧសភា ឆ្នាំ២០០៧។

ចៅក្រមអន្តរជាតិ សង្ឃឹមថាអង្គជំនុំជម្រះវិសាមញ្ញអាចឈានទៅមុខដោយគ្មានការបង្អែរបង្អង់ទៀត ដើម្បីអនុវត្តន៍តួនាទីរបស់ខ្លួននៃការទទួលខុសត្រូវ ចំពោះមុខប្រវត្តិសាស្ត្រ ក្នុងការស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា។